ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ អន្តរាគមន៍ជួយនារីខ្មែររងគ្រោះ៣នាក់

******

តាមការណែនាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ បានសហការជាមួយអាជ្ញាធរចិន អន្តរាគមន៍ជួយនារីខ្មែរ**៣នាក់** ដែលមេខ្យល់បោកបញ្ឆោតយកទៅរៀបការជាមួយបុរសជនជាតិចិន អោយបានត្រឡប់មកកម្ពុជាវិញ៖

(១) នារីឈ្មោះ **ធ.ព** អាយុ២៧ឆ្នាំ មកពីខេត្តកំពង់ចាម

(២) នារីឈ្មោះ **ធ.ម.ល** អាយុ១៦ឆ្នាំ មកពីខេត្តកំពង់ចាម

(៣) នារីឈ្មោះ **ស.ជ.ន** អាយុ២៦ឆ្នាំ មកពីខេត្តព្រៃវែង

នារីទាំង**៣នាក់** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៨** ខែ **ធ្នូ** ឆ្នាំ **២០១៦** វេលាម៉ោង**២៣:១៥នាទី** តាមជើងយន្តហោះMU759 ។ អំឡុងពេលរង់ចាំមកកម្ពុជាវិញ ស្ថានអគ្គកុងស៊ុលបានរ៉ាប់រងផ្តល់កន្លែងស្នាក់នៅនិងអាហារបរិភោគ ដល់នារីរងគ្រោះទាំង**៣នាក់**ផងដែរ។

ជាថ្មីម្តងទៀត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមអំពាវនាវដល់ពលរដ្ឋខ្មែរទាំងអស់ សូមមានការប្រុងប្រយ័ត្នអោយបានខ្ពស់ ចំពោះមេខ្យល់ឬជនណាដែលប្រើលាភសក្ការៈ ដើម្បីអូសទាញ បញ្ចុះបញ្ចូល និងបោកបញ្ឆោត ប៉ុនប៉ងយកទៅរៀបការជាមួយជនបរទេស ឬធ្វើការខុសច្បាប់នៅតាមប្រទេសនានា៕

ភ្នំពេញ, ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ